គណៈកម្មាធិការប្រព្រឹត្តិកម្ម គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច

# សេចក្តីថ្លែងការណ៍រួម

## ស្តីពី

## អង្គការសង្គមស៊ីវិលអំពាវនាវឱ្យបញ្ឈប់ហឹង្សានយោបាយ នៅតំណាក់កាលយុទ្ធនាការឃោសនាបោះឆ្នោត

*ភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨*

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ដែលជាសម្ព័ន្ធអង្គការ-សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ២១, គណៈកម្មាធិការខុមហ្វ្រែល មានសមាជិកចំនួន ១០អង្គការ-សមាគម **និងគណៈកម្មាធិការនិកហ្វិច**មានសមាជិកចំនួន៧អង្គការ-សមាគមសំដែងនូវការព្រួយបារម្ភជាខ្លាំងស្ថានភាពនយោបាយជាទូទៅ និងការអនុវត្តន៏លទ្ធិប្រជាធិបតេយ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅក្នុងតំណាក់កាលឃោសនាបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអាណត្តិទី៤ នេះ។

អង្គការសង្គមស៊ីវិលបានកត់សំគាល់ឃើញថា នៅក្នុងតំណាក់កាលឃោសនាបោះឆ្នោតដែលចាប់ផ្តើមពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៨ រហូតមកទល់ពេលនេះ មានកើតឡើងនូវអំពើហឹង្សានយោបាយប្រឆាំងជាពិសេសទៅនឹងសកម្មជនគណបក្សនយោបាយមិនកាន់អំណាចទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដែលបាននិងកំពុងគំរាមកំហែងដល់សេរីភាពក្នុងការចូលរួមឱ្យបានពេញលេញនៅក្នុងពេលបោះឆ្នោតជាតិខាងមុខ។ សេរីភាពសារព័ត៌មាននេះ គឺជាសមាសធាតុដ៏សំខាន់ នៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាយើង ហើយសេរីភាពនេះក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ អង្គការសង្គមស៊ីវិលក៏បានសង្កេតឃើញថា ក្នុងរយៈពេលឃោសនាបីសប្តាហ៍កន្លងមកនេះ មានករណីហឹង្សានយោបាយបានកើតឡើងដូចជា: ការគំរាមកំហែងនិងការសំលាប់អ្នកសារព័ត៌មាន និងសកម្មជនរបស់គណបក្សមិនកាន់អំណាច ដែលឈានទៅដល់ការធ្វើឱ្យចុះខ្សោយ នៃស្ថានភាពសន្តិសុខជាទូទៅ ហើយដែលបង្កើតឱ្យមានការភ័យខ្លាចដល់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។

ទោះបីជាចំនួនសរុប នៃ ករណីហឹង្សានយោបាយ ហាក់ដូចជាមានចំនួនតិចជាង កាលពីរយៈពេលឃោសនាបោះឆ្នោត នៅពេលបោះឆ្នោតមុនៗក៏ដោយ ក៏អង្គការសង្គមស៊ីវិលបានសង្កេតឃើញ និងមានការព្រួយបារម្ភជាខ្លាំងទៅលើករណីដូចខាងក្រោមនេះ

- **ឃាតកម្មលើសកម្មជនគណបក្សនយោបាយ និង ឃាតកម្មផ្សេងៗ មានចំនួន ១១ករណី**
- **ការរំខានឃាយី និង គំរាមកំហែងលើសកម្មជនគណបក្សនយោបាយ មានចំនួន ២៥ករណី**
- **ការទំលាក់ និងបំផ្លាញផ្លាកគណបក្សនយោបាយ មានចំនួន ១២ករណី**
- **ការរារាំងឃោសនាបោះឆ្នោត មានចំនួន ៨ករណី**
- **ការរំលោភនីតិវិធីឃោសនាបោះឆ្នោត មានករណី ៩ករណី**
- **ការទិញសន្លឹកឆ្នោត មាន ៧ករណី**

ទាក់ទិននឹងករណីទាំងអស់នេះ អង្គការសង្គមស៊ីវិលពិនិត្យឃើញថា ជនប្រព្រឹត្តបទល្មើសភាគច្រើនមិនទាន់ត្រូវបានចាប់ខ្លួនដើម្បីយកទៅផ្តន្ទាទោសតាមច្បាប់ និងមិនទាន់មានចំណាត់ការផ្លូវច្បាប់ឱ្យបានម៉ឺងម៉ាត់ណាមួយពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីលុបបំបាត់ និងរារាំងុំឱ្យមានការប្រព្រឹត្តសកម្មភាពបែបនេះនៅពេលអនាគតទៀត។

អង្គការសង្គមស៊ីវិលបានដឹងថា នៅក្នុងកំឡុងពេលឃោសនាបោះឆ្នោតនេះ ស្ថានភាពនយោបាយ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យ នឹងមិនមានភាពល្អប្រសើរឡើយ ប្រសិនបើករណីនៃហឹង្សានយោបាយ នៅតែបន្តកើតមានដូចស្ថានភាពបច្ចុប្បន្ននេះ។ ដូចនេះការណ៍នឹងអាចនាំឱ្យប៉ះពាល់ទៅដល់គោលការណ៍បោះឆ្នោតដោយសេរីនិងយុត្តិធម៌ និងឆន្ទៈដោយសេរីរបស់ប្រជាពលរដ្ឋម្ចាស់ឆ្នោត ដែលនឹងចូលរួមនៅក្នុងពេលបោះឆ្នោតខាងមុខនេះផងដែរ។

ដើម្បីឱ្យការបោះឆ្នោតនាពេលខាងមុខនេះប្រព្រឹត្តទៅមានលក្ខណៈសេរី និងយុត្តិធម៌ អង្គការសង្គមស៊ីវិលខាងលើ សូមផ្តល់អនុសាសន៍សំខាន់ៗដូចខាងក្រោមៈ

- រាជរដ្ឋាភិបាលនិងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវតែចាត់វិធានការស៊ើបអង្កេតដ៏គួរឱ្យទុកចិត្តចំពោះករណីនៃអំពើហឹង្សានយោបាយដែលបានកើតឡើងកន្លងមក និងស្វែងរកចាប់ខ្លួនជនល្មើសទាំងនោះយកទៅផ្តន្ទាទោសតាមច្បាប់។
- រាជរដ្ឋាភិបាលត្រូវចាត់វិធានការជាបន្ទាន់ និងប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសន្តិសុខ នៅក្នុងប្រទេសទាំងមូល ជាពិសេសអំពើគំរាមកំហែងទៅសុវត្ថិភាពបុគ្គល ដើម្បីធានាឱ្យមានការចូលរួមពីសំណាក់អ្នកបោះឆ្នោតឱ្យកាន់តែច្រើនរបស់ដោយគ្មានការភ័យខ្លាច និងគ្មានការគំរាមកំហែងនៅពេលបោះឆ្នោតខាងមុខនេះ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវតែចាត់វិធានការទប់ស្កាត់ បង្ការបទល្មើស និង ឆ្លើយតបឱ្យបានទាន់ពេលវេលានូវរាល់ពេលដែលមានប្រជាពលរដ្ឋប្តឹងពីការគំរាមកំហែងនានា ដែលប៉ះពាល់ដល់អាយុជីវិតរបស់គេ។
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវតែធ្វើការដោយអព្យាក្រិត្យ និងឯករាជ្យពីការជាប់ពាក់ព័ន្ធជាមួយនឹងគណបក្សនយោបាយ និងត្រូវដោះស្រាយពាក្យបណ្តឹងឱ្យទាន់ពេលវេលា និងដោយយុត្តិធម៌ ប្រសិនបើមានបណ្តឹងពីគណបក្សនយោបាយដាក់បញ្ជូនមក។
- គណបក្សនយោបាយ គួរគោរពគ្នាទៅវិញទៅមកក្នុងសេចក្តីថ្លៃថ្នូរ និងប្រកបដោយភាពចាស់ទុំខាងនយោបាយ ដើម្បីឱ្យការបោះឆ្នោតជាតិខាងមុខនេះ ប្រព្រឹត្តទៅដោយយុត្តិធម៌ និងដោយស្មើភាព។
- កងកំលាំងប្រដាប់អាវុធ និង អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ត្រូវប្រកាន់ជំហរឯករាជ្យ និង អព្យាក្រឹត្យ ក្នុងការបំពេញភារកិច្ច និង តួនាទីរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ ដើម្បីធានាបរិយាកាសនយោបាយប្រកបដោយសុខសន្តិភាព និងផ្តល់ទំនុកចិត្តពីសំណាក់ប្រជាពលរដ្ឋម្ចាស់ឆ្នោត។


**<u>សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ</u>**

| | | |
|---|---|---|
| - លោក **សុក សំអឿន** | នាយកប្រតិបត្តិ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា / អ្នកសម្របសម្រួលគណៈកម្មាធិការប្រព្រឹត្តិកម្មស្តីទី | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| - លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ ខុមហ្វ្រែល | ទូរស័ព្ទលេខ : ០១២ ៩៤២ ០១៧ |
| - លោក **ហង្ស ពុទ្ធា** | នាយកប្រតិបត្តិ និកហ្វិច | ទូរស័ព្ទលេខ : ០១២ ៩៥៩ ៦៦៦ |
| - លោក **នី ចរិយា** | ប្រធានផ្នែកអង្កេតសមាគមអាដហុក | ទូរស័ព្ទលេខ: ០១១ ២៧៤ ៧៥៩ |
| - លោក **អ៊ឹម សុភា** | ជំនួការប្រតិបត្តិ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម | ទូរស័ព្ទលេខ: ០១៦ ៨៨៨ ៥៥២ |